ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧.០១៧.៣២៣ ប្រ.ក

# ប្រកាស
# ស្តីពី
# លក្ខណៈសម្គាល់នៃធនប័ត្រ ប្រភេទ ១០០០ រៀល គំរូថ្មី

***********

អនុលោមតាមអនុក្រឹត្យលេខ ១៨៣ អនក្រ.បក របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៧ ស្តីពីការចេញផ្សាយធនប័ត្រប្រភេទ១០០០ រៀល គំរូថ្មី ក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារជាតិនៃកម្ពុជាសូមប្រកាសផ្សាយជាសាធារណៈនូវលក្ខណៈសំគាល់នៃធនប័ត្រគំរូថ្មីនេះ មានដូចខាងក្រោម ៖

**ក- លក្ខណៈទូទៅ ៖**

- ទំហំធនប័ត្រ ៖ បណ្តោយ ១៤២ មម និងទទឹង ៦៨ មម
- ពណ៌ចម្បង គឺពណ៌ផ្ទៃមេឃ ពណ៌ខៀវ និងពណ៌លឿងទុំ ។

**ខ- ផ្ទៃខាងមុខនៃធនប័ត្រ ៖**

- **ផ្នែកកណ្តាល** ខាងស្តាំត្រូវបានរំលេចឡើងនូវព្រះឆាយាល័ក្ខណ៍នៃ **ព្រះបរមរតនកោដ្ឋ ព្រះបាទនរោត្តមសីហនុវរ្ម័ន** កាលពីព្រះអង្គទ្រង់គង់ប្រថាប់ក្នុងព្រះបរមរាជសម្បត្តិ ខាងឆ្វេងមានលេខ "១០០០" នៅពីលើគេ បន្ទាប់មកគឺជាហត្ថលេខារបស់ទេសាភិបាលនិងអគ្គបេឡា ព្រមទាំងរូបភាពតែងលំអយកតាមរូបក្បាច់ហោជាងនៃប្រាសាទក្នុងព្រះបរមរាជវាំង និងនៅពីក្រោមនោះមានលេខ-មាលាបោះពុម្ពដោយទឹកខ្មៅពណ៌ខ្មៅ រូបចម្លាក់នាគក្បាល ៥ នៅប្រាសាទបឹងមាលា និងអក្សរ "មួយពាន់រៀល" ព្រមទាំងអក្សរ "អ្នកក្លែងក្រដាសប្រាក់នឹងត្រូវផ្តន្ទាទោសតាមច្បាប់" នៅគែមខាងក្រោមនោះ ។

- **ផ្នែកខាងស្តាំ** ជ្រុងលើមានអក្សរ "ធនាគារជាតិនៃកម្ពុជា" ព្រមទាំងលេខ-មាលាបោះពុម្ពដោយទឹកខ្មៅពណ៌ក្រហម និងជ្រុងក្រោមមានលេខ "១០០០" ព្រមជាមួយលេខ "1000" នៅពីក្រោមនោះ ។

- **ផ្នែកខាងឆ្វេង** មានលេខ "1000" ព្រាលៗបោះពុម្ពតាមបន្ទាត់បញ្ឈរ ព្រមទាំងរូបភាពតែងលំអពណ៌ប្រាក់យកលំនាំតាមក្បាច់ចម្លាក់នៅប្រាសាទបន្ទាយស្រី បោះពុម្ពកាត់ទទឹងក្រដាស

ប្រាក់ពីលើដល់ក្រោម និងជ្រុងក្រោមមានគំនូសបន្ទាត់ខ្លីៗជាច្រើនបង្កើតឡើងដោយលេខ " ១០០០ " ដ៏តូចល្អិត ។

**គ- ផ្ទៃខាងខ្នងនៃធនប័ត្រ ៖**

**- ផ្នែកកណ្តាល** ត្រូវបានរំលេចឡើងនូវរូបភាពព្រះទីនាំងទេវាវិនិច្ឆ័យមើលបញ្ឆិតពីជ្រុងមុខខាងឆ្វេង និងនៅពីក្រោមនោះ មានអក្សរ " មួយពាន់រៀល " ។

**- ផ្នែកខាងស្តាំ** ជ្រុងលើមានលេខ " 1000 " បោះពុម្ពតាមបន្ទាត់បញ្ឈរ នៅកណ្តាលជារូបចម្លាក់គ្រុឌឈរទ្រថែងប្រាសាទព្រះរាជដំណាក់ច័ន្ទ និងនៅជ្រុងក្រោមមានលេខ" ១០០០ " ។

**- ផ្នែកខាងឆ្វេង** ជ្រុងលើមានអក្សរ "ធនាគារជាតិនៃកម្ពុជា" អក្សរ " NATIONAL BANK OF CAMBODIA " និងលេខ " 2016 " នៅកណ្តាលមានរូបភាពព្រាលៗនៃរូបចម្លាក់ដាក់តាំងក្នុងព្រះបរមរាជវាំងនៃអតីតព្រះមហាក្សត្រព្រះបាទនរោត្តមទ្រង់គង់ប្រថាប់លើព្រះទីនាំងពាជីព្រមជាមួយក្បាច់លំអពណ៌ប្រាក់ផ្តុំឡើងដោយលេខ " ១០០០" ផ្ទុយគ្នា និងនៅជ្រុងក្រោមមានលេខ " ១០០០" ។

ចាប់ពីថ្ងៃចេញប្រកាសនេះតទៅ ធនប័ត្រប្រភេទ ១០០០ រៀល គំរូថ្មី ត្រូវបានដាក់ឲ្យធ្វើចរាចរទន្ទឹមគ្នាជាមួយនឹងធនប័ត្រជាតិប្រភេទផ្សេងៗទៀតដែលត្រូវបានចេញផ្សាយរួចមកហើយ។ សាធារណជនគ្រប់រូបត្រូវពិនិត្យ-សម្គាល់ធនប័ត្រគំរូថ្មីនេះឲ្យបានច្បាស់លាស់ ដើម្បីជៀសវាងការភ័ន្តច្រឡំ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៧

**ទេសាភិបាល**

**ជា ចាន់តូ**